ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍

លេខ ២៦២ គសអ

# សេចក្តីសម្រេច

## ស្តីពី

## ការអនុញ្ញាតឲ្យប្រើប្រាស់ប្រឡង់ដៃពាក់សម្គាល់កម្លាំងប្រជាការពារ ក្នុងយុទ្ធនាការការពារការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ៦ ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃអាទិត្យទី ២៩ ខែកក្កដា ឆ្នាំ២០១៨

## គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១២៦ អនក្រ.បក ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍(គ.ស.អ)
- បានឃើញសេចក្តីសម្រេចលេខ ៨៦ សសរ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ២០១៦ ស្តីពីការបង្កើតលេខាធិការដ្ឋាននៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍
- សេចក្តីណែនាំរួមលេខ ០០១ គសអ ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០១៧ រវាងគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ និង គ.ជ.ប ស្តីពីសកម្មភាព និងការរៀបចំភ្នាក់ងារសន្តិសុខបោះឆ្នោតការពារការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨
- យោងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨
- យោងប្រតិទិននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨
- យោងតាមការចាំបាច់របស់គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ ។

## សម្រេច

**ប្រការ ១ :** ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ប្រឡង់ដៃ សម្រាប់ពាក់សម្គាល់កម្លាំងប្រជាការពារ ដែលបានចាត់តាំងឲ្យចូលរួមប្រចាំការជួយអន្តរាគមន៍នៅតាមភូមិសាស្ត្រឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌនៃរាជធានី ខេត្ត និង





www.pheakdeylaw.com

កម្លាំងប្រជាការពារដែលការពារនៅតាមទីស្នាក់ការគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) ក្នុងយុទ្ធនាការការពារការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអាទិត្យទី ២៩ ខែកក្កដា ឆ្នាំ២០១៨ ។

**ប្រការ ២ :** **រូបភាព ពណ៌ និងខ្នាតប្រឡង់ដៃ**

ប្រឡង់ដៃនីមួយៗត្រូវបានផលិតពីកំណាត់តេតារ៉ុង ពណ៌ផ្ទៃមេឃ និងដេរលិនជាយដោយអំបោះពណ៌ផ្ទៃមេឃមានបណ្តោយប្រវែង ៥០ សង់ទីម៉ែត្រ និងមានទទឹងប្រវែង ១២ សង់ទីម៉ែត្រ ដែលនៅចំកណ្តាលផ្ទៃប្រឡង់ដៃគឺមានសរសេរអក្សរពណ៌សជាបីជួរ ដូចខាងក្រោម ៖

-ជួរលើមានសរសេរអក្សរ " **គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍** "

-ជួរកណ្តាលមានសរសេរអក្សរ " **ប្រជាការពារ** "

-ជួរក្រោមមានសរសេរអក្សរ " **ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៨** "

ប្រឡង់ដៃនីមួយៗត្រូវបានដេរភ្ជាប់ពីចុងម្ខាងទៅចុងម្ខាងទៀត ដែលមានសណ្ឋានដូចជារាងបំពង់កាត់ ។

**ប្រការ ៣ :** **អំពីរបៀបពាក់ និងរយៈពេលនៃការប្រើប្រាស់ប្រឡង់ដៃ**

កម្លាំងប្រជាការពារ ដែលបានចាត់តាំងឲ្យចូលរួមប្រចាំការជួយអន្តរាគមន៍ ការពារការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ៦ ចាំបាច់ត្រូវពាក់ប្រឡង់ដៃនៅដើមដៃខាងឆ្វេងរបស់ខ្លួន ដោយត្រូវដាក់បង្ហាញឲ្យគេមើលឃើញច្បាស់នូវតួអក្សរពណ៌សទាំងបីជួរស្ថិតនៅចំផ្ទៃកណ្តាលប្រឡង់ដៃ ដូចកំណត់ក្នុងប្រការ ២ ខាងលើ ។

កម្លាំងប្រជាការពារត្រូវបានអនុញ្ញាតឲ្យពាក់ប្រឡង់ដៃ ចាប់ពីថ្ងៃទី ២៧ ដល់ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៨ ។

**ប្រការ ៤ :** សេចក្តីសម្រេចនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះទៅ ។

ថ្ងៃពុធ ១១ រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ពស២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៨
**ប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍**

**សម្តេចក្រឡាហោម ស ខេង**

**<u>កន្លែងទទួល</u>** ៖

- ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- អគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ
- អគ្គលេខាធិការដ្ឋាន គ.ជ.ប
- លេខាធិការដ្ឋាន គ.ស.អ
- គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី-ខេត្ត
- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី-ខេត្ត
- បញ្ជាការដ្ឋានតំបន់ប្រតិបត្តិការសឹករងរាជធានី-ខេត្ត
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com